**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខៈ ៣៤៣ ប.ក សក

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ២០១៧

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យយានយន្ត ធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ២១៦អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន



មហាវិថីព្រះនរោត្តម, ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥) ២៣ ៤២៧ ៨៦២

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងគ្រប់គ្រងយានជំនិះដែលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក និងការដឹកជញ្ជូនទំនិញនិងអ្នកដំណើរតាមយានជំនិះ។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅដូចខាងក្រោម៖

- កំណត់លក្ខខណ្ឌ និងនីតិវិធីនៃការអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក
- កំណត់បរិមាណទំនិញគិតជា **តោន/គ.ម** ឬអ្នកដំណើរគិតជា **នាក់/គ.ម**។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះយានជំនិះ ដែលប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ និងដឹកជញ្ជូនអ្នកដំណើរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ត្រូវបានលើកលែងចំពោះរថយន្តជាកម្មសិទ្ធិរដ្ឋដែលបម្រើសេវាដឹកជញ្ជូនសាធារណៈ។

**ប្រការ៤.-**

យានយន្ត រ៉ឺម៉ក ដែលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក ត្រូវមានលិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ហើយត្រូវដាក់តាមយានយន្តជាប្រចាំ នៅគ្រប់ពេលធ្វើចរាចរណ៍នៅតាមផ្លូវថ្នល់។

នីតិបុគ្គល រូបវន្តបុគ្គល ឬតំណាងស្របច្បាប់ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស តាមគំនូសបំព្រួញដូចមានចែងក្នុង**ឧបសម្ព័ន្ធទី១**និងនីតិវិធីខាងក្រោម៖

- ត្រូវដាក់ពាក្យស្នើសុំតាមប្រព័ន្ធស្វ័យប្រវត្តិកម្មស្នើសុំធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកដែលមានអាសយដ្ឋាន transportlicense.mpwt.gov.kh និងបង់ប្រាក់កម្រៃសេវាសាធារណៈតាមប្រព័ន្ធស្វ័យប្រវត្តិកម្មទៅដៃគូណាមួយដែលធ្វើប្រតិបត្តិការជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន
- ពាក្យស្នើសុំនឹងត្រូវបានអនុម័ត ក្រោយពេលបង់ប្រាក់រួច និងពិនិត្យឃើញថាត្រឹមត្រូវតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- ក្រោយការអនុម័តលើពាក្យស្នើសុំ អ្នកដាក់ពាក្យនឹងត្រូវបានជូនដំណឹង ឲ្យយកសំណុំឯកសារដើម ភ្ជាប់ជាមួយនឹងពាក្យស្នើសុំ និងវិក្កយបត្របង់ប្រាក់ ទៅទីតាំងផ្តល់សេវាដែលកំណត់ដោយក្រសួង ដើម្បីផ្ទៀងផ្ទាត់ថាពិតជាត្រឹមត្រូវដើម្បីប្តូរយកលិខិតអនុញ្ញាត។

ទម្រង់ឯកសារភ្ជាប់នឹងពាក្យស្នើសុំរួមមាន៖

- បណ្ណសម្គាល់យានយន្ត
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះដែលមានសុពលភាព
- លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសចំពោះក្រុមហ៊ុន។

**ប្រការ៥.-**

យានយន្តជាសមាជិករបស់ភ្នាក់ងារផ្តល់សេវាដឹកជញ្ជូនដោយចែករំលែកយានជំនិះ មិនតម្រូវឲ្យមានលិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មទេ។

**ប្រការ៦.-**

លិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស មានសុពលភាព ១(មួយ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញ។

លិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស មួយច្បាប់ប្រើប្រាស់សម្រាប់តែយានជំនិះមួយគ្រឿងប៉ុណ្ណោះ។

**ប្រការ៧.-**

ទម្រង់ពាក្យសុំ និងទម្រង់លិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស មានចែងនៅក្នុង**ឧបសម្ព័ន្ធទី២**នៃប្រកាសនេះ។

**ប្រការ៨.-**

ការចេញលិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស ត្រូវបង់កម្រៃសេវាសាធារណៈតាមការកំណត់ក្នុងប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ៩.-**

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ត្រូវគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងណែនាំអនុវត្តការចេញលិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស។

**ប្រការ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១១.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ អគ្គនាយកនៃអគ្គនាយកដ្ឋានផែនការនិងគោលនយោបាយ អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារកម្ម អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានជំនាញ ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីខេត្ត ប្រធានអង្គភាពក្រោមឱវាទក្រសួងសាធារណការនិងដឹកជញ្ជូន និងអ្នកពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តរៀងៗខ្លួន តាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- សាលារាជធានីខេត្ត

  "ដើម្បីជូនជ្រាប"
- ដូចប្រការ១១

  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

គំនូសបំព្រួញអំពីដំណើរការផ្តល់លិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក
ក្នុងប្រទេស

ប្រកាសលេខ.................... ចុះថ្ងៃទី...... ខែ......... ឆ្នាំ.................

ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក
ក្នុងប្រទេស




**សម្គាល់៖** ប្រព័ន្ធស្វ័យប្រវត្តិកម្មស្នើសុំធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកមានអាសយដ្ឋាន transportlicense.mpwt.gov.kh

## ឧបសម្ព័ន្ធទី២

ទម្រង់ពាក្យសុំ និងទម្រង់លិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស
ដែលត្រូវបោះពុម្ពចេញពីប្រព័ន្ធស្វ័យប្រវត្តិកម្មស្នើសុំធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក
ដោយមានព័ត៌មាននីតិបុគ្គល ឬរូបវន្តបុគ្គល និងព័ត៌មានយានយន្តភ្ជាប់មកជាមួយស្រាម
ប្រកាសលេខ...................... ចុះថ្ងៃទី....... ខែ.......... ឆ្នាំ..................
ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោក
ក្នុងប្រទេស

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំលិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេស

នាមនិងគោត្តនាម.................................................................ភេទ............សញ្ជាតិ............
អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ.........................................
អាសយដ្ឋានបច្ចុប្បន្ន - ផ្ទះលេខ...............ផ្លូវ..............ភូមិ.....................សង្កាត់/ឃុំ......................
ខណ្ឌ/ក្រុង/ស្រុក...........................................រាជធានី/ខេត្ត........................................................
លេខទូរស័ព្ទ........................................ អ៊ីម៉ែល.................................................... ។

យានយន្ត មានភិនភាគដូចខាងក្រោម៖
ផ្លាកលេខ..............................................................ម៉ាក ...............................................
ប្រភេទ..................................................................កម្លាំងសេះ:.......................................
ពណ៌.....................................................................ទម្ងន់ទទេ .......................................
លេខម៉ាស៊ីន...........................................................ចំណុះផ្ទុក.........................................
លេខសាក់ស៊ី..........................................................ទម្ងន់សរុប.......................................
លេខតួ..................................................................។
ធ្វើអាជីវកម្មដឹក...........................ពី.........................ដល់.....................តាមផ្លូវ...................។

ធ្វើនៅ.......................ថ្ងៃទី.........ខែ...............ឆ្នាំ.............

ហត្ថលេខា ឬស្នាមមេដៃ

**ឯកសារភ្ជាប់៖**

- បណ្ណសម្គាល់យានយន្ត
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះដែលមានសុពលភាព
- លិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសចំពោះក្រុមហ៊ុន។

**សម្គាល់៖**

- ការដាក់ពាក្យស្នើសុំបន្ទាប់ មិនចាំបាច់មានចុះហត្ថលេខាឬស្នាមមេដៃទេ លើកលែងតែមានការផ្លាស់ប្តូរកម្មសិទ្ធិបណ្ណសម្គាល់យានជំនិះ ឬផ្លាកលេខយានជំនិះ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក
លេខៈ..................................................

# លិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ

ម្ចាស់អាជីវកម្មឈ្មោះ.........................................................................................................
អាសយដ្ឋាន.........................................................................................................
.........................................................................................................
.........................................................................................................
ផ្លាកលេខ..................................................ប្រភេទ.................................................
ម៉ាក..........................................ពណ៌..........................................ចំនួនកៅអី......................
លេខតួ............................លេខសាក់ស៊ី..............................លេខម៉ាស៊ីន.............................
កម្លាំងសេះ.............................ទម្ងន់យាន..........................(គ.ក)ទម្ងន់សរុប.....................(គ.ក)
លេខវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត..........................................................
អនុញ្ញាតឲ្យផ្ទុកអ្នកដំណើរ...................................(នាក់)ទម្ងន់ភារវត្ថុ............................ (គ.ក)
ទិសដៅពី.......................ដល់.........................តាមផ្លូវ................ក្នុងព្រះរាជាណាចក្រកម្ពុជា។

កាលបរិច្ឆេទចេញ.....................................................................

កាលបរិច្ឆេទផុតសុពលភាព...............................................។

លិខិតអនុញ្ញាតនេះ មិនចាំបាច់មានហត្ថលេខា
The Signature is not required in this Permit

**សម្គាល់៖** លិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរមានទំហំ B5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក
លេខ៖.................................................

# លិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ

ម្ចាស់អាជីវកម្មឈ្មោះ........................................................................................................
អាសយដ្ឋាន.......................................................................................................................
.......................................................................................................................
.......................................................................................................................
ផ្លាកលេខ......................................................ប្រភេទ.................................................
ម៉ាក.........................................ពណ៌.........................................លេខតួ.................................
លេខសាក់ស៊ី...........................................លេខម៉ាស៊ីន..................................................
កម្លាំងសេះ......................ទម្ងន់យាន......................... (គ.ក) ទម្ងន់សរុប............................. (គ.ក)
លេខវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត..............................................................
អនុញ្ញាតឲ្យផ្ទុកទំនិញ............................................. (គ.ក)និងអនុញ្ញាតឲ្យធ្វើអាជីវកម្មដឹកជញ្ជូនទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

កាលបរិច្ឆេទចេញ.................................................................................
កាលបរិច្ឆេទផុតសុពលភាព.................................................................។

លិខិតអនុញ្ញាតនេះ មិនចាំបាច់មានហត្ថលេខា
The Signature is not required in this Permit

**សម្គាល់៖** លិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនទំនិញក្នុងប្រទេស មានទំហំ B5